# វង់ភ្លេងក្មេងៗតាមភូមិ

## Ratana and Meakara's Village Orchestra

អង្គការរ៉ឺម៉កកង់បី
សម្រាប់កុមារ R4C



Written by TukTuk
Illustrated by Hen Choven



ថ្ងៃមួយ យ៉េកបានទៅទទួលរតនានិងមករាត្រលប់ពីពិធីមង្គលការសាច់ញាតិរបស់ពួកគេ។ យ៉េកបានឃើញពួកគេច្រៀង រាំនិងទះដៃយ៉ាងសប្បាយរីករាយ។

«វ៉ាវ! អ្នកទាំងពីរមើលទៅសប្បាយណាស់!» យ៉េកនិយាយ។





«ចាស! ពិតជាសប្បាយមែន» រតនានិយាយទាំងញញឹម។

«យើងបានឃើញនារីរបាំប្រាំនាក់ រាំរបាំជូនពរ ដើម្បីជូនពរដល់គូស្វាមីភរិយាថ្មី និងការប្រគុំវង់ភ្លេងប្រពៃណីខ្មែរ»។

«ក្រុមវង់ភ្លេងបានអនុញ្ញាតឱ្យយើងលេងឈិងនិងស្គរដៃតូច» មករានិយាយ។

«ប៉ុន្តែមិនអាចលេងតាខេបានទេ ព្រោះងាយនឹងដាច់ខ្សែ» រតនាបន្ថែម។


សួស្ដីអាពាហ៍ពិពាហ៍









«កាលនៅពីក្មេង ខ្ញុំនិងមិត្តភក្តិបានបង្កើតក្រុមវង់ភ្លេង» យ៉េកនិយាយ។
«តើអ្នកអាចបង្កើតឧបករណ៍ភ្លេងពិតបានដែរឬទេ?» រតនាសួរ។
យ៉េកបានសើចហើយនិយាយ «ទេ! មិនមែនជារបស់ពិតទេ។
ទាល់តែអ្នកមានជំនាញទើបអាចផលិតឧបករណ៍ភ្លេងពិតបាន។
ចំណែកយើងអាចប្រើសម្ភារជុំវិញផ្ទះ ដើម្បីផលិតជាឧបករណ៍ភ្លេង។
តើអ្នកចង់សាកបង្កើតក្រុមវង់ភ្លេងខ្មែរដោយខ្លួនឯងដែរឬទេ?
ខ្ញុំនឹងទៅបបួលខេទី ហើយអ្នកអាចបបួលមិត្តភក្តិរបស់អ្នកបាន»។






«តើយើងអាចធ្វើឈិងដូចខ្ញុំលេងក្នុងវង់តន្ត្រីបានទេ?» មករាសួរ។

«មិនពិបាកនោះទេ! រកគម្របឆ្នាំងពីរមកគោះគ្នា ឬដុំថ្មពីរគោះគ្នាក៏បានដែរ» យ៉េកបាននិយាយ។

កុមារផ្សេងទៀតបាននិយាយ «ឬក៏យកឈើពីរគោះគ្នាក៏បានដែរ! មានសំឡេងច្រើនណាស់ខុសៗគ្នា»។


ឈិង




«ខ្ញុំចង់ធ្វើប៉ីពកឬប៉ីអ» មិត្តភក្តិរបស់រតនានិយាយទាំងអៀន។

«អ្នកត្រូវការទុយោរ ហើយចោះរន្ធខ្លះៗ» យ៉េកបាននិយាយ។

«ខ្ញុំនឹងធ្វើតាខេមួយ ដោយប្រើប្រអប់នេះជាមួយកៅស៊ូមួយចំនួន» រតនាបាននិយាយ ហើយពួកគេបានចាប់ផ្តើមបង្កើតឧបករណ៍វង់ភ្លេងផ្ទាល់ខ្លួន។


ប៉ីពក
ប៉ីអ
តាខេ




«តើយើងអាចធ្វើរនាតដែលជាវង់ភ្លេងពិណពាទ្យបានដែរឬទេ?» មករាសួរ។

«តស់សាកល្បង! ខេទីអាចជួយយើងបាន» យ៉េកបាននិយាយ។

«អ្នកត្រូវការរកឈើវែងពីរនិងឈើឬឬស្សីជាច្រើន»។

ខេទីនិងមករាត្រលប់មកវិញជាមួយឈើនិងឬស្សីជាច្រើន។


រនាតធុង



«អស្ចារ្យណាស់! យកឈើវែងពីរធ្វើជាស្នូក រួចយកឈើខ្លីៗគងពីលើធ្វើជាផ្លែរនាត។ ប្រើក្រណាត់រុំក្បាលឈើចំនួនពីរ ធ្វើជាអន្លូងគោះរនាត។ តស់សាកល្បងលេង! តម្រៀបឈើពីក្រាស់មកស្តើង ដើម្បីឱ្យសំឡេងរនាតឮពីទាបទៅខ្ពស់» យ៉េកបាននិយាយ។

«ពិតជាសប្បាយពិតមែន!» មករាសើច។






«ចុះស្គរខ្មែរវិញ?» ក្មេងម្នាក់បានសួរ។

«វាមិនពិបាកនោះទេ អាចប្រើអ្វីក៏បាន។

យើងយកធុង កំប៉ុងសំណប៉ាហាំង ឆ្នាំងបាយនិងឆ្នាំងសម្ល»។

«តស់ទៅរកសម្ភារ!» យ៉េកបាននិយាយ។


ស្គរដៃ



លោកគ្រូសុខបានដើរចូលក្នុងភូមិបណ្ដើរ បិទត្រចៀកបណ្ដើរ។
«តើទាំងអស់គ្នាកំពុងធ្វើអ្វី សំឡេងអ៊ូអរម្ល៉េះ?» គាត់សួរ។
«ក្រុមពួកយើងកំពុងប្រគុំវង់ភ្លេងប្រពៃណីខ្មែរ!» កុមារម្នាក់បាននិយាយ។
«ពួកយើងបានបង្កើតក្រុមវង់ភ្លេងប្រពៃណីខ្មែរដោយខ្លួនឯង!»





លោកគ្រូសុខនិយាយទាំងញញឹម

«តើអ្នកត្រូវការអ្នកដឹកនាំក្រុមវង់ភ្លេងប្រពៃណីខ្មែរដែរឬទេ?»។

«នៅពេល ខ្ញុំយកដំបងមកគ្រវីជាសញ្ញា ក្រុមវង់ភ្លេងប្រពៃណីខ្មែរត្រូវតែដេញ ផ្លុំ ទះ ឬគោះឧបករណ៍ភ្លេង!»។





«ត្រៀមខ្លួនហើយឬនៅ? មួយ ពីរ បី... ចាប់ផ្ដើមប្រគុំហើយ!»
បើលោកគ្រូសុខគ្រវីដំបងលឿនៗ ក្រុមវង់ភ្លេងប្រគុំលឿនៗ។
បើលោកគ្រូសុខគ្រវីដំបងយឺតៗ ក្រុមវង់ភ្លេងប្រគុំយឺតៗ។
បើលោកគ្រូសុខគ្រវីដំបងតិចៗ ក្រុមវង់ភ្លេងប្រគុំឮតិចៗ។
បើលោកគ្រូសុខគ្រវីដំបងខ្លាំងៗ ក្រុមវង់ភ្លេងប្រគុំឮខ្លាំងៗតាមដែលអាចធ្វើទៅបាន។
គ្រប់គ្នាសើចសប្បាយរីករាយជាមួយក្រុមវង់ភ្លេងប្រពៃណីខ្មែររបស់ពួកគេ។






# វង់ភ្លេងក្មេងៗតាមភូមិ

អ្នកនិពន្ធ៖ TukTuk

អ្នកគំនូរ៖ ហ៊ិន ឆវិន

គំនូរជីវចល

ធនធានបង្រៀន

អង្គការរ៉ឺម៉កកង់បី សម្រាប់កុមារ R4C

TUKTUK

Rotary